# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

********

# កិច្ចសន្យាសងប្រាក់ជំពាក់

នាងខ្ញុំ សំប៊ុន យ៉ានី អ្នកគ្រប់គ្រងហិរញ្ញវត្ថុ នៃ មណ្ឌលពត៌មានស្ត្រីកម្ពុជា សូមបញ្ជាក់ និង ធ្វើកិច្ចសន្យាជាថ្មីថា ដោយសារ ការដោះស្រាយមិនទាន់ក្នុងការរកលុយមកសងអង្គការមណ្ឌលពត៌មានស្ត្រីកម្ពុជាឲ្យទាន់ដូចកិច្ចសន្យាធ្វើនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ដែលបានសន្យាថានឹងរកលុយមកសងនៅថ្ងៃទី ម្ភៃប្រាំមួយ ខែ វិច្ឆិកា ឆ្នាំ ២០១៣ នោះ នាងខ្ញុំសូមឲ្យក្រុមប្រឹក្សាភិបាលទុកពេលឲ្យនាងខ្ញុំ រកដំណោះស្រាយ។

នៅក្នុង ចុងខែធ្នូ ឆ្នាំ ២០១៣ នេះ នាងខ្ញុំ នឹងអាចសងមកមណ្ឌលពត៌មានបានពី ៦ (ប្រាំមួយ) ម៉ឺន ទៅ ១០ (ដប់) ម៉ឺន ដុល្លា និង សងបង្គ្រប់ចំនួន ២៥៨,៩៧៩.៨២ ដុល្លា ដែលនាងខ្ញុំជំពាក់សារុប នៅក្នុងខែកុម្ភៈ ឆ្នាំ ២០១៤។ ក្នុងករណី ដែលនាងខ្ញុំរកលុយបានចំនួនណាមួយ មុនថ្ងៃកំណត់ នាងខ្ញុំនឹងយកមកសងជាបន្តបន្ទាប់។

នាងខ្ញុំ សន្យាថានឹងមិនចាកចេញ ឬ រត់ចោល បំណុលនេះទេ និង មិនចាកចេញក្រៅប្រទេសនោះឡើយ កាលបើមិនទាន់សងលុយគ្រប់ ឬ មិនមានការយល់ព្រមពីក្រុមប្រឹក្សាមណ្ឌលពត៌មានស្ត្រីកម្ពុជាជាមុន។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

ស្នាមមេដៃស្តាំ

សំប៊ុន យ៉ានី

អ្នកស្រី សំប៊ុន យ៉ានី បានផ្តិតមេដៃស្តាំ

នៅចំពោះមុខខ្ញុំ មេធាវី សុក សំអឿន

ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី សុក សំអឿន

24/02/2017

@ 11:30AM

គោរពជូន

ក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យតាលីអានស្ត្រីកម្ពុជា

នាងខ្ញុំឈ្មោះ ស៊ីវុន ម៉េងនី អ្នកគ្រប់គ្រងហិរញ្ញវត្ថុ
នៃមន្ទីរពេទ្យតាលីអានស្ត្រីកម្ពុជា បានយកប្រាក់ពីការសន្សំ
ដោយគ្មានការអនុញ្ញាតពី លោកស្រី នាយិកាប្រតិបត្តិ
មន្ទីរពេទ្យតាលីអានស្ត្រីកម្ពុជា ចំនួន US$258,979.82
(ពីរសែនហាសិបប្រាំបីពាន់ ប្រាំបួនរយចិតសិបប្រាំបួន
ដុល្លារអាមេរិក ប៉ែតសិបពីរសេន) ដើម្បីយកទៅ
ឲ្យប្អូនស្រីនៅ Newzealands (ស្វាល់ខ្ញុំ)។
នាងខ្ញុំ ស៊ីវុន ម៉េងនី សូមសន្យាថានឹងសង ប្រាក់ចំនួននេះ
[illegible]
[illegible] ~~[struck]~~ ពីរពាន់សិប [illegible]។

[illegible]
មន្ទីរពេទ្យតាលីអានស្ត្រីកម្ពុជា [illegible]

សាក្សីទី២ សាក្សីទី១ ក្នុង [illegible] ភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ២០១៣

ម៉ែន សុភក្រ ម៉ោចៅ្រៃ ឃាកិត ស៊ីវុន ម៉េងនី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យារ៉ាប់រងសងប្រាក់

ខ្ញុំបាទ ឈ្មោះ ហៅ ស៊ីឌី ភេទ ប្រុស អាយុ ២៧ ឆ្នាំ មុខរបរ សាស្ត្រាចារ្យ ផ្នែកពត៌មានវិទ្យា នៃ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និង ភរិយា ឈ្មោះ ជោពេជ្រ មរកត អាយុ ២៩ ឆ្នាំ មានទីលំនៅនៅ ផ្ទះលេខ ០១ ផ្លូវ ៨៦ សង្កាត់ ស្រះចក ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ,

សូមគោរពចូលមក

គណៈគ្រប់គ្រង នៃ មណ្ឌលពត៌មានស្ត្រីកម្ពុជា

សូមទានជ្រាប។

កម្មវត្ថុះ ការសន្យារ៉ាប់រងសងប្រាក់។
យោងតាមះ កិច្ចសន្យារ៉ាប់រងសងប្រាក់ របស់យើងខ្ញុំចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៤។

យើងខ្ញុំ ពីរនាក់ស្វាមី ភរិយា សូមជំរាបមកអស់លោក លោកស្រី សមាជិក សមាជិកា នៃ គណៈគ្រប់គ្រង នៃ មណ្ឌលពត៌មានស្ត្រីកម្ពុជាថា ខ្ញុំបាទនឹងទទួលរ៉ាប់រងសងប្រាក់ដែល អ្នកស្រី សំប៊ុន យ៉ានី ដែលត្រូវជាម្តាយក្មេក នៅជំពាក់ប្រាក់មណ្ឌលពត៌មានស្ត្រីកម្ពុជា នៅសល់ចំនួន ២០៨,៩៧៩.៨២ ដុល្លា (ម្ភៃម៉ឺនប្រាំបីពាន់ប្រាំរយចិតសិបប្រាំបួន និង ប៉ែតសិបពីរសេន) ដែលជាចំនួន នៅសល់បន្ទាប់ពីយើងខ្ញុំទាំងពីរបានសងមជ្ឈមណ្ឌលកន្លងមកហើយ។

ខ្ញុំបាទ និង នាងខ្ញុំ សូមសន្យាថា បន្ទាប់ពីទទួលបាននូវប្រទានកម្មរបស់ម្តាយ-ម្តាយក្មេក នៅពេលណា យើងខ្ញុំនឹងចាត់ចែងសងបំណុលនេះ។ ក្នុងករណីនៅបំណាច់ឆ្នាំ ២០១៨ យើងខ្ញុំនៅតែ មិនមានលទ្ធភាពចេញសងបំណុលនេះទេ យើងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ ។

ធ្វើនៅការិយាល័យលោកមេធាវី សុក សំអឿន
ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៧

| ស្នាមមេដៃស្តាំ | ស្នាមមេដៃស្តាំ |
|---|---|
| ហៅ ស៊ីឌី | ជោពេជ្រ មរកត |

លេខ ៤៩ អ១៧
អ្នកទាំងពីរ បានផ្តិតមេដៃលើលិខិតកិច្ចសន្យារ៉ាប់រង សងនេះនៅចំពោះមុខយើង មេធាវី សុក សំអឿន។
ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៧

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី សុក សំអឿន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យារ៉ាប់រងសងប្រាក់

ខ្ញុំបាទ ឈ្មោះ **ហៅ សីឌី** ភេទ ប្រុស អាយុ ២៨ ឆ្នាំ មុខរបរ សាស្ត្រាចារ្យ ផ្នែកពត៌មានវិទ្យា នៃ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានទីលំនៅនៅ ផ្ទះលេខ ១៦៨ អឺ០ ផ្លូវព្រះសីហនុ សង្កាត់ បឹងកេងកង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ,

និង

នាងខ្ញុំឈ្មោះ **ដោពេជ្រ មរកត** អាយុ ២៦ ឆ្នាំ មុខរបរ ម្ចាស់ភាគហ៊ុនក្រុមផលិតវីឌីអូ ឈ្មោះ ត្រេនហ្ស៍មីឌា TRENDZ MEDIA មានទីលំនៅនៅ ផ្ទះលេខ ២៤៤ ផ្លូវ ១៥៦ សង្កាត់ ទឹកល្អក់ ២ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ។

សូមគោរពចូលមក

ក្រុមប្រឹក្សានាយក នៃ មណ្ឌលពត៌មានស្ត្រីកម្ពុជា

សូមទានជ្រាប។

កម្មវត្ថុ៖ ការសន្យារ៉ាប់រងសងប្រាក់។

ខ្ញុំបាទ សូមជំរាបមកអស់លោក លោកស្រី ជាក្រុមប្រឹក្សានាយក នៃ មណ្ឌលពត៌មានស្ត្រីកម្ពុជាថា ខ្ញុំបាទនឹងទទួលរ៉ាប់រងសងប្រាក់ដែល អ្នកស្រី សំប៊ុន យ៉ានី ដែលត្រូវជាអនាគតម្ដាយក្មេក នៅជំពាក់ប្រាក់មណ្ឌលពត៌មានស្ត្រីកម្ពុជា ចំនួន ២១៨,៩៧៩.៨២ ដុល្លា នៅពេលណា ដែលម្ដាយបង្កើតរបស់ខ្ញុំបែងចែកទ្រព្យសម្បត្តិ ក្រោយពេលដែលយើងខ្ញុំបានរៀបការ ហើយនៅក្រោយពេលចូលឆ្នាំខ្មែរ និង មិនហួសដំណាច់ឆ្នាំ ២០១៥។

ខ្ញុំបាទសូមបញ្ជាក់ផងដែរថា តាមពិតប្រាក់នេះត្រូវបាននៅក្នុងឆ្នាំនេះ ប៉ុន្តែ ដោយសារយើងខ្ញុំទាំងពីរឆុងឆ្នាំ មិនអាចរៀបការបាននៅក្នុងឆ្នាំនេះ ហើយចៃដន្យអាក្រក់ជីដូនបង្កើត

របស់ខ្ញុំបាទទើបតែនឹងទទួលមរណភាព កាលពីថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៤ ពិធីមង្គលការរបស់យើងខ្ញុំនឹងលើកទៅឆ្នាំក្រោយ និង កំណត់ថ្ងៃក្រោយចូលឆ្នាំខ្មែរហើយ។

ទោះជាក្នុងករណីណាក៏ដោយ ខ្ញុំបាទ និង អនាគតភរិយាខ្ញុំ គឺនាង ជៅពេជ្រ មរកត សូមសន្យាថា នឹងរ៉ាប់រងទទួលសងបំណុលនេះឲ្យទាល់តែបាន។ ចំពោះការសុំឲ្យយើងខ្ញុំបង់ការប្រាក់ យើងខ្ញុំសូមការអនុគ្រោះពីក្រុមប្រឹក្សានាយក អនុគ្រោះ ព្រោះបន្ទុកនេះមានភាពធំធេងសម្រាប់យើងខ្ញុំរួចទៅហើយ។

លិខិតនេះសូមចាត់ទុកជាកិច្ចសន្យារបស់យើងខ្ញុំតាមផ្លូវច្បាប់ចំពោះ មណ្ឌលពត៌មានស្ត្រីកម្ពុជា លើកលែងតែក្រុមប្រឹក្សានាយកនៃមណ្ឌលពត៌មានស្ត្រីកម្ពុជាជំទាស់។

ធ្វើនៅការិយាល័យលោកមេធាវី សុក សំអឿន
ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៤

ស្នាមមេដៃស្តាំ — ស្នាមមេដៃស្តាំ

ហៅ សុីឌី — ជៅពេជ្រ មរកត

សាក្សី

ឈា - ស៊ុនថិតារ៉ាត

លេខ ១៨២ អ១៤

អ្នកទាំងពីរ គឺលោក ហៅ សុីឌី និង
អ្នកនាង ជៅពេជ្រ មរកត
បានផ្តិតមេដៃលើលិខិតកិច្ចសន្យារ៉ាប់រងសង
នេះនៅចំពោះមុខយើង។
ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៤

មេធាវី សុក សំអឿន
ក្រុមប្រឹក្សានាយក និង ជាតំណាងដោយអណត្តិ
ឲ្យក្រុមប្រឹក្សានាយកមណ្ឌលពត៌មានស្ត្រីកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ

នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ខ្ញុំមេធាវី សុក សំអឿន បានធ្វើការសំភាសន៍ លោក អ៊ិត វិរៈ ភេទ ប្រុស អាយុ ២៧ ឆ្នាំ បច្ចុប្បន្នជា មានមុខងារជា មន្ត្រីហិរញ្ញវត្ថុ Finance Officer នៃអង្គការពត៌មានស្ត្រីកម្ពុជា ពាក់ព័ន្ធនឹងការយកប្រាក់របស់អង្គការរបស់អ្នកស្រី សំប៊ុន យ៉ានី អ្នកគ្រប់គ្រងហិរញ្ញវត្ថុ ដែលមានខ្លឹមសារដូចតទៅ៖

សធ០១៖ ខ្ញុំបាទបានចូលធ្វើការនៅក្នុងអង្គការនេះ នៅក្នុង មេសា ឆ្នាំ ២០០៩ ក្នុងឋានៈជាគណនេយ្យករ។ ការចូលធ្វើការនេះ ខ្ញុំបានដឹងពត៌មានពីការជ្រើសរើសនេះពី កញ្ញា ពេជ្រ មរកត ដែលត្រូវជាកូនស្រីរបស់ អ្នកស្រី សំប៊ុន យ៉ានី ។

សធ០២៖ មុនដំបូងខ្ញុំបាទមិនបានដឹងពីបញ្ហា ដែលអ្នកស្រី សំប៊ុន យ៉ានី យកខ្ទីលុយរបស់អង្គការ ដោយមិនត្រឹមត្រូវនេះទេ ព្រោះពេលចូលដំបូងខ្ញុំបាទនៅធ្វើជាគណនេយ្យករ ដែលមិនមានកិច្ចការ ក្នុងការធ្វើរបាយការណ៍អ្វីទេ។ រហូតមកដល់ដើមឆ្នាំ ២០១១ ខ្ញុំបានត្រូវចាត់តាំងឲ្យទទួលខុសត្រូវគម្រោងមួយ ឈ្មោះ រ៉ូហ្សាលុចសំបួរ ហ្វោនដេស្ទិន ROSA LUXEMBURG FOUNDATION ។

សធ០៣៖ប្រហែលជាដោយសារ ខ្ញុំត្រូវបានកាន់តំណែង ជាអ្នកទទួលខុសត្រូវគម្រោងបែបនេះ ហើយ ថ្ងៃមួយ អ្នកស្រី សំប៊ុនយ៉ានី បានហៅខ្ញុំទៅជួប ហើយបានសួរខ្ញុំថា តើខ្ញុំមានដឹងអីទេ។

សធ០៤៖ ពេលនោះខ្ញុំមិនបានដឹងរឿងគាត់នោះទេ ប៉ុន្តែខ្ញុំបានឆ្លើយថា ខ្ញុំដឹងខ្លះៗដែរ។

សង០៥៖ ភ្លាមនោះ អ្នកស្រី សំប៊ុន យ៉ានី ក៏បានប្រាប់ខ្ញុំពីរឿងគាត់បានលួចខ្ចីប្រាក់របស់អង្គការ ដែលនៅពេលនោះ គាត់បានខ្ចីដល់ទៅជាង ១០ម៉ឺនដុល្លា។

សង០៦៖ ខ្ញុំបានសម្រេចចិត្តមិនទម្លាយអាថ៌កំបាំងនេះទេ ដោយសារខ្ញុំអាណិតគាត់ ហើយជឿថាគាត់នឹងសងអង្គការវិញឲ្យអស់នៅចុងឆ្នាំ ដោយគាត់ថាយកលុយនោះឲ្យប្អូននៅកាណាដាខ្ចី ហើយគេនឹងសងវិញនៅបំណាច់ឆ្នាំ ២០១១។

សង០៧៖ ប៉ុន្តែ នៅចុងឆ្នាំ ២០១១ គាត់បានហៅក្រុមហិរញ្ញវត្ថុទាំងអស់មកប្រជុំ កាលណោះមាន អ្នកស្រី ម៉ែន សុគន្ធារី, អ្នកស្រី ម៉ា គឹមសឿន, លោក ហេង សុចិត្រា និង ខ្ញុំ, គាត់ក៏បានសុំទោសពួកខ្ញុំទាំងអស់គ្នា ដែលគាត់មិនទាន់បានសងលុយអង្គការវិញដោយសារមូលហេតុ ដែលគាត់បានរៀបរាប់មកគួរឲ្យខ្ញុំបាទទុកចិត្ត។ ពួកយើងក៏បន្តបិទមាត់តទៅទៀត។

សង០៨៖ នៅក្នុង ខែ មិនា ឆ្នាំ ២០១៣, ខ្ញុំបានស្វែងរកការងារទីកន្លែងផ្សេងធ្វើ ដោយសារខ្ញុំបាទ ចង់ផ្លាស់ប្តូរបទពិសោធន៍ តែអ្វីដែលសំខាន់ ខ្ញុំមិនចង់ពាក់ព័ន្ធនឹងរឿងនេះផង។

សង០៩៖ តែដោយសារពេលនោះ អ្នកស្រី ម៉ែន សុគន្ធារី បានលាឈប់មុន ហើយអ្នកស្រី សំប៊ុន យ៉ានី បានអង្វរខ្ញុំពេក ខ្ញុំក៏សម្រេចចិត្តនៅបន្តទៅទៀត។

សង១០៖ នៅក្នុងរបាយការណ៍ គឺពួកយើងមិនបានបំភ្លៃ ឬ បំផ្លើសនោះទេ ពោលគឺលុយទាំងនោះដាក់ ថា ជាថវិការកំពុងដំណើរការ ដែលជាទូទៅ គឺមិនអាចនៅយូរបានទេ ហើយ ដែលតាមពិតបើអ្នកគណនេយ្យ ឬ ហិរញ្ញវត្ថុ គឺអាចមើលទៅមានការសង្ស័យ ឬដឹងបាន។

សង១១៖រាល់ពេលដែលគាត់បង្វិលលុយទាំងនោះ ខ្ញុំបាទបានដឹងដែរ គឺគាត់ដកបង្វិលទៅសងទូទាត់បំណុលចាស់។ ប៉ុន្តែពេលខ្លះខ្ញុំមិនបានដឹងថាគាត់យកថែមទេ ព្រោះលុយដែលដកបានតំកល់ទុកលុយសុទ្ធជាបណ្តោះអាសន្នមុននឹងបង្វិលចូលគណនីមួយទៀត។

សឆ១២៖ខ្ញុំដឹងថាគាត់បានខ្ចីលុយអង្គការចំនួន ២៥ ម៉ឺនដុល្លាជាងនឹងគឺនៅពេល ដែលខ្ញុំធ្វើរបាយការណ៍ហិរញ្ញវត្ថុសារុប នៅក្នុងខែ ឧសភា ឆ្នាំ ២០១៣។

សឆ១៣៖ បន្ទាប់ពីលោកមេធាវី សុក សំអឿន បានសំភាសន៍ខ្ញុំចប់ លោកបានឲ្យ ខ្ញុំបាទ អានកំណត់ហេតុ និង បើកសិទ្ធិឲ្យខ្ញុំបាទធ្វើការកែតម្រូវនូវចំណុចដែលមិនស្របទៅនឹងចំលើយរបស់ខ្ញុំបាទ។

សឆ១៤៖ ក្រែងពុំប្រាកដ ខ្ញុំបាទសូមផ្តិតមេដៃស្តាំទុកជាចំណាំស្រាប់ និង ហ៊ានទទួលខុសត្រូវចំពោះមុខច្បាប់កាលបើខ្ញុំបាទនិយាយមិនពិតខុសពីចំណាំ និង ការចងចាំរបស់ខ្ញុំ។

សំភាសន៍នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣

ហត្ថលេខាសាម៉ីខ្លួន

អ៊ុត វិរៈ

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី សុក សំអឿន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ

នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ខ្ញុំមេធាវី សុគា សំអឿន បានធ្វើការសំភាសន៍ លោកស្រី ម៉ា គឹមសឿន ភេទ ស្រី អាយុ ៥៧ ឆ្នាំ បច្ចុប្បន្នជា មានមុខងារជា មន្ត្រីចំណាយ Disbursement Officer នៃអង្គការពត៌មានស្ត្រីកម្ពុជា ពាក់ព័ន្ធនឹងការយកប្រាក់ របស់អង្គការ របស់អ្នកស្រី សំប៊ុន យ៉ានី អ្នកគ្រប់គ្រងហិរញ្ញវត្ថុ ដែលមានខ្លឹមសារដូចតទៅៈ

សធ០១៖ នាងខ្ញុំ បានចូលធ្វើការនៅក្នុងអង្គការនេះ តាំងពីខែ មិនា ឆ្នាំ ១៩៩៦ ក្នុងឋានៈជាគណនេយ្យករ ទទួលខុសត្រូវកិច្ចការគណនេយ្យរបស់អង្គការ ដោយសារពេលនោះ ធ្លាប់បានធ្វើការជាមួយគ្នានឹងអ្នកស្រី ជា ស៊ុនជាណែត នៅអ៊ិនតាក់។

សធ០២៖ នៅឆ្នាំ ២០០៣ អង្គការបានជ្រើសរើស អ្នកស្រី សំប៊ុន យ៉ានី ជាមន្ត្រីហិរញ្ញវត្ថុ នាងខ្ញុំ ដោយសារនាងខ្ញុំមិនមានសញ្ញាប័ត្រធំដុំ នាងខ្ញុំ ក៏ត្រូវបានចាត់តាំង ជាមន្ត្រីចំណាយតាំងពីពេលនោះមក។

សធ០៣៖ នៅក្នុងឆ្នាំ ២០១០ នាងខ្ញុំ បានដែរដឹងថា អ្នកស្រី សំប៊ុន យ៉ានី បានលួចខ្ចីលុយអង្គការដោយមិនឲ្យថ្នាក់លើដឹង។ ពេលនោះ ដោយយល់ឃើញថាជាអ្នកធ្វើការជាមួយគ្នា នាងខ្ញុំក៏ទៅនិយាយឲ្យគាត់យកលុយមកសងអង្គការវិញ ហើយប៉ុន្មានខែក្រោយមក អ្នកស្រី សំប៊ុន យ៉ានី ក៏យកលុយមកដាក់ឲ្យអង្គការវិញ ហើយលុយនោះក៏មិនជាច្រើនប៉ុន្មានដែរ។ នៅពេលនោះ គាត់ក៏មានការខ្ចក់ចិត្តនឹងនាងខ្ញុំដែរ ដោយហេតុនេះហើយ បានជានៅពេលនោះ គាត់បាន កោរសក់ម្តង។

សធ០៤៖ ពី ថ្ងៃទី ១១ ខែ មិនា ដល់ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១១, នាងខ្ញុំមានជម្ងឺត្រូវវះតម្រងនោម ហើយក៏សម្រាកព្យាបាលអស់អស់រយៈពេលមួយខែនោះ។

សធ០៥៖ ក្នុងកំឡុងពេលនោះនាងខ្ញុំ គិតថាគាត់នឹងមិនប៉ះពាល់លុយអង្គការវិញទេ។ ក្នុងខែមិថុនា ឆ្នាំ ២០១១ ក្រោយដែលបានចូលធ្វើការវិញ នាងខ្ញុំ ក៏មានការសង្ស័យថាគាត់

យកលុយទៀត នាងខ្ញុំក៏ធ្លាប់បានបន្លយពាក្យថា កុំចង់យកប្រយោជន៍ខ្លួនឯង ធ្វើឲ្យក្មេងៗ ខូចអនាគត។ ហេតុនេះ
ហើយបានជាគាត់មិនសូវជាសប្បាយចិត្តនឹងនាងខ្ញុំទេ ហើយនាងខ្ញុំក៏មិនដឹងថាគាត់យកលុយប៉ុន្មានៗដែរ។

សធ០៦៖ នៅចុងឆ្នាំ ២០១១ ពេលដែលនៅជុំគ្នាក្នុងបន្ទប់ គាត់ក៏បានប្រាប់ពួកខ្ញុំទាំងអស់គ្នា កាលណោះមាន អ្នកស្រី ម៉ែន សុគន្ធារី, លោក ហេង សុចិត្រា, លោក អ៊ិត វិរៈ និង ខ្ញុំ, គាត់ក៏បានសុំទោសពួកខ្ញុំទាំងអស់គ្នា ដែលគាត់មិនទាន់បានសងលុយអង្គការវិញ ហើយដែលអាចធ្វើឲ្យប៉ះពាល់ដល់អនាគតពួកខ្ញុំ និង ក្មេងៗ។ ដោយសារគាត់ថានឹងសង ហើយនាងខ្ញុំ ក៏មិនដឹងថាគាត់យកលុយអង្គការប៉ុន្មាននោះទេ ហើយម្យ៉ាងខ្ញុំយល់ថា វាតិចតួចដូចមុនអញ្ចឹង។

សធ០៧៖ ក្រោយមក នាងខ្ញុំ ក៏បានប្រាប់ លោក អ៊ិត វិរៈ ថាត្រូវតែឲ្យគាត់សងអង្គការវិញជាបន្ទាន់ ជាពិសេសត្រូវតែឲ្យគាត់ធ្វើលិខិតស្នាមថាជំពាក់ប៉ុន្មានៗ ទើបជាការត្រឹមត្រូវ។

សធ០៨៖ នាងខ្ញុំមិនដឹងទាល់តែសោះថាគាត់យកលុយរហូតដល់រាប់ម៉ឺននេះ នាងខ្ញុំហ៊ានស្បថ គឺថានាងខ្ញុំទើបតែនឹងដឹងនៅពេលដែលលោកមេធាវីសួរខ្ញុំពេលនេះទេ។

សធ០៩៖ បន្ទាប់ពីលោកមេធាវី សុក សំអឿន បានសំភាសន៍ខ្ញុំចប់ លោកបានឲ្យ នាងខ្ញុំអានកំណត់ហេតុ និង បើកសិទ្ធិឲ្យនាងខ្ញុំធ្វើការកែតម្រូវនូវចំណុចដែលមិនស្របទៅនឹងចំលើយរបស់នាងខ្ញុំ។

សធ១៤៖ ក្រែងពុំប្រាកដ នាងខ្ញុំសូមផ្តិតមេដៃស្តាំទុកជាចំណាំស្រាប់ និង ហ៊ានទទួលខុសត្រូវចំពោះមុខច្បាប់កាលបើនាងខ្ញុំនិយាយមិនពិតខុសពីចំណាំ និង ការចងចាំរបស់នាងខ្ញុំ។

សំភាសន៍នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣

ហត្ថលេខាសាមីខ្លួន

ម៉ា គីមសឿង

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី សុក សំអឿន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ

នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ខ្ញុំមេធាវី សុភា សំអឿន បានធ្វើការសំភាសន៍ លោក ហេង សុចិត្រា ភេទ ប្រុស អាយុ ២៧ ឆ្នាំ បច្ចុប្បន្នជា មានមុខងារជា គណនេយ្យករ Accountant នៃអង្គការពតិមានស្ត្រីកម្ពុជា ពាក់ព័ន្ធនឹងការយកប្រាក់របស់អង្គការរបស់អ្នកស្រី សំប៊ុន យ៉ានី អ្នកគ្រប់គ្រងហិរញ្ញវត្ថុ ដែលមានខ្លឹមសារដូចតទៅ៖

សធ០១៖ ខ្ញុំបាទបានចូលធ្វើការនៅក្នុងអង្គការនេះ នៅក្នុង ធ្នូ ឆ្នាំ ២០១០ ក្នុងឋានៈជា គណនេយ្យករ។ ការចូលធ្វើការនេះ មិនមានតាមរយៈនរណាម្នាក់ទេ ។

សធ០២៖ មុនដំបូងខ្ញុំបាទមិនបានដឹងពីបញ្ហា ដែលអ្នកស្រី សំប៊ុន យ៉ានី យកខ្ចីលុយរបស់ អង្គការ ដោយមិនត្រឹមត្រូវនេះទេ ព្រោះក្នុងឋានៈគណនេយ្យករ គឺមិនមានកិច្ចការ ក្នុងការធ្វើរបាយការណ៍អ្វីទេ។

សធ០៣៖តែថ្ងៃមួយ ក្នុងពាក់កណ្តាលឆ្នាំ ២០១១ ខ្ញុំបាទ បានដឹងថា អ្នកស្រី សំប៊ុន យ៉ានី មានការពាក់ព័ន្ធនឹងការខ្ចីលុយអង្គការដោយមិនឲ្យថ្នាក់លើដឹង តាមរយៈ លោក អ៊ុត វិរៈ លួចប្រាប់ខ្ញុំ។

សធ០៤៖ ប្រហែល ១ សប្តាហ៍ ក្រោយមក នៅពេលថ្ងៃមួយដែលស្ងាត់ អ្នកស្រី សំប៊ុន យ៉ានី បានទម្លាយប្រាប់ខ្ញុំដោយផ្ទាល់ថា គាត់បានលួចខ្ចីប្រាក់របស់អង្គការ តែសុំឲ្យខ្ញុំជួយ លាក់ជាការសម្ងាត់ ហើយគាត់នឹងសងឲ្យអស់នៅដំណាច់ឆ្នាំ។

សធ០៥៖ ខ្ញុំបានសម្រេចចិត្តមិនទម្លាយអាថ៌កំបាំងនេះទេ ដោយសារខ្ញុំអាណិតគាត់ គាត់ជា អ្នកដឹកនាំល្អ ចេះជួយកូនចៅ និង ជួយបណ្តុះបណ្តាលខ្ញុំ ហើយជឿថាគាត់នឹងសង អង្គការវិញឲ្យអស់នៅចុងឆ្នាំ ដោយគាត់ថាមានប្អូននៅកាណាដាជាអ្នកជួយសងវិញនៅ បំណាច់ឆ្នាំ ២០១១។

**សឆ០៦៖** ប៉ុន្តែ នៅចុងឆ្នាំ ២០១១ ពេលដែលនៅជុំគ្នាក្នុងបន្ទប់ គាត់ក៏បានប្រាប់ពួកខ្ញុំទាំងអស់គ្នា កាលណោះមាន អ្នកស្រី ម៉ែន សុគន្ធារី, អ្នកស្រី ម៉ា គឹមសឿន, លោក អ៊ិត វិរៈ និង ខ្ញុំ, គាត់ក៏បានសុំទោសពួកខ្ញុំទាំងអស់គ្នា ដែលគាត់មិនទាន់បានសងលុយអង្គការវិញ ហើយដែលអាចធ្វើឲ្យប៉ះពាល់ដល់អនាគតពួកខ្ញុំក្មេងៗ ដោយសារមូលហេតុដែលគាត់បានរៀបរាប់មកគួរឲ្យខ្ញុំបាទទុកចិត្ត។ ពួកយើងក៏បន្តបិទមាត់តទៅទៀត។

**សឆ០៧៖** ការដែលខ្ញុំជួយបិទបាំងគាត់ ខ្ញុំក៏យល់ថាជាការមិនគប្បីនឹងក្រមសីលធម៌អ្នកគណនេយ្យដែរ ហើយនេះជាមូលហេតុដែលខ្ញុំសម្រេចចិត្តនឹងលាឈប់នៅដំណាច់ឆ្នាំនេះ បន្ទាប់ពី អ្នកស្រី សំប៊ុន យ៉ានី សងទៅអង្គការរួចរាល់។ ប៉ុន្តែជាថៃដន្យ រឿងនេះក៏បែកធ្លាយក្នុងពេលនេះទៅ។

**សឆ០៨៖** ខ្ញុំដឹងថាគាត់បានខ្ចីលុយអង្គការចំនួន ២៥ ម៉ឺនដុល្លាជាងប្រមាណជាពីរបីខែមុននេះប៉ុណ្ណោះ តាមរយៈ លោក អ៊ិត វិរៈជាអ្នកប្រាប់។

**សឆ០៩៖** បន្ទាប់ពីលោកមេធាវី សុក សំអឿន បានសំភាសន៍ខ្ញុំចប់ លោកបានឲ្យ ខ្ញុំបាទអានកំណត់ហេតុ និង បើកសិទ្ធិឲ្យខ្ញុំបាទធ្វើការកែតម្រូវនូវចំណុចដែលមិនស្របទៅនឹងចំលើយរបស់ខ្ញុំបាទ។

**សឆ១៤៖** ក្រែងពុំប្រាកដ ខ្ញុំបាទសូមផ្តិតមេដៃស្តាំទុកជាចំណាំស្រាប់ និង ហ៊ានទទួលខុសត្រូវចំពោះមុខច្បាប់កាលបើខ្ញុំបាទនិយាយមិនពិតខុសពីចំណាំ និង ការចងចាំរបស់ខ្ញុំ។

សំភាសន៍នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣

ហត្ថលេខាសាមីខ្លួន

ហេង សុចិត្រា

មេធាវី សុក សំអឿន

10-21-13

# Women's Media Centre of Cambodia
## Reconciliation Detail
### 10-1120 · Global Current Account, Period Ending 30-09-2013

| Type | Date | Num | Name | Memo | Clr | Amount | Balance |
|---|---|---|---|---|---|---|---|
| Check | 30-09-2013 | 13-2244 | Uth Sophea | Clear adv.for field visit & technical support for LVCs 18-20/sep/13 and LVC meeting 19-23/Sep/13... | | 0.00 | 0.00 |
| Check | 27-09-2013 | 13-2218 | SPIDER | Refund to Global C/A | | 1.00 | 1.00 |
| Check | 27-09-2013 | 13-2200 | WMC SGI:WMC SGI | Refund to Global C/A | | 13.03 | 14.03 |
| Check | 30-08-2013 | 13-1937 | WMC SGI:WMC SGI | Refund to Global C/A | | 18.00 | 32.03 |
| Check | 30-09-2013 | 13-2242 | AECID:AECID ST | Transfer AECID C/A to Salary Tax C/A for staff salary tax of Mr.Reach Lila for Sept 13 | | 23.46 | 55.49 |
| Check | 30-09-2013 | 13-2240 | RLS | Refund to Global C/A | | 25.78 | 81.27 |
| Check | 27-09-2013 | 13-2211 | WMC SGI:WMC SGI | Refund to Global C/A | | 28.87 | 110.14 |
| Check | 27-09-2013 | 13-2217 | NOVIB 2013:Novib Program 13 | Refund to Global C/A | | 42.03 | 152.17 |
| Check | 26-09-2013 | 13-2193 | PACT | Refund to Global C/A | | 56.00 | 208.17 |
| Check | 30-09-2013 | 13-2243 | UNOPS | Refund to Global C/A | | 81.47 | 289.64 |
| Check | 30-09-2013 | 13-2244 | Forum Syd | Refund to Global C/A | | 87.83 | 377.47 |
| Check | 30-09-2013 | 13-2242 | AECID:AECID KRT | Transfer AECID C/A to Salary Tax C/A for staff salary tax of Ms. Hin Kunthea and Mr.Samrith Tona... | | 98.92 | 476.39 |
| Check | 27-09-2013 | 13-2197 | WMC SGI:WMC SGI | Refund to Global C/A | | 160.00 | 636.39 |
| Check | 31-07-2013 | 13-1635 | WMC SGI:WMC SGI | Refund to global C/A | | 1,378.72 | 2,015.11 |
| Check | 30-09-2013 | 13-2241 | NOVIB 2013:Novib Adm 13 | Refund to Global C/A | | 1,710.00 | 3,725.11 |
| Check | 02/08/2013 | 13-1665 | AECID:AECID | Transfer spending projection to Global C/A | | 7,000.00 | 10,725.11 |
| Check | 19-06-2013 | 13-1200 | WMC SGI:WMC SGI | Transfer WMC SGI spending project to Global C/A | | 20,000.00 | 30,725.11 |
| Check | 05-07-2013 | 13-1413 | WMC SGI:WMC SGI | Transfer WMC SGI spending project to Global C/A | | 30,000.00 | 60,725.11 |
| Check | 12/09/2013 | 13-2045 | WMC SGI:WMC SGI | Transfer WMC SGI spending project to Global C/A | | 17,259.51 | 77,984.62 |
| Sales Receipt | 15-08-2013 | 13-0161 | UNOPS | Clear SGI Advance to UNOPS for spending projection for Quarter I, Apr-Jun/13 | | 20,000.00 | 97,984.62 |
| Check | 21-08-2013 | 13-1776 | WMC SGI:WMC SGI | Transfer WMC SGI spending project to Global C/A | | 25,000.00 | 122,984.62 |
| Sales Receipt | 22-04-2013 | 13-0081 | NOVIB 2013 | Clear SGI Advance to Novib for spending projection for 2013 | | 40,000.00 | 162,984.62 |
| Check | 28-12-2012 | 12-3224 | WMC SGI:WMC SGI | Transfer SGI ACLEDA EURO S/A to SGI Global USD C/A (EUR 12,744.14 x 1.3120 = $16,720.31) | | 16,720.31 | 179,704.93 |
| Check | 28-12-2012 | 12-0028 | WMC SGI:WMC SGI | Transfer WMC SGI spending project tot Global C/A | | 83,000.00 | 262,704.93 |
| Total Deposits and Credits | | | | | | 262,704.93 | 262,704.93 |
| Total Uncleared Transactions | | | | | | 234,170.01 | 234,170.01 |
| Register Balance as of 30-09-2013 | | | | | | 206,730.81 | 248,402.69 |
| **Ending Balance** | | | | | | **206,730.81** | **248,402.69** |

**Total Yany's Balance: $258,979.82**

## Bank Reconciliation Statement for the year of 2012 -WMC

| Month | | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec | No Supporting Docs 2012 | No Supporting Docs 2013 | TOTAL |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Balance Per Bank Statement | | 153,759.17 | 58,884.35 | 73,317.72 | 160.17 | 11,458.49 | 55,722.55 | 45,757.68 | | 19,196.69 | 34,136.37 | 34,539.74 | 47,842.17 | | | |
| Add: | Deposit not realize_Supporting docs | | 5,304.45 | 2,374.98 | 2,374.39 | 2,374.39 | 4,581.81 | 3,654.73 | 2462.09 | 3,415.69 | 4,306.83 | 24,080.94 | 126,906.80 | | | |
| | Deposit not realize- No Supporting Docs | 83,000.00 | 83,000.00 | 83,000.00 | 83,000.00 | 83,000.00 | 83,000.00 | 83,000.00 | 83,000.00 | 83,000.00 | 83,000.00 | 83,000.00 | 99,720.31 | 99,720.31 | 159,259.51 | 258,979.82 |
| | Others-Supporting documents | | | | | | | | | | | | | | | |
| | Others- No Supporting documents | | | | | | | | | | | | | | | |
| Less: | Outstanding Checks- Supporting Documents | (14,497.14) | (19,518.53) | (12,697.09) | (15,955.79) | (14,227.19) | (23,721.71) | (22,776.02) | | (20,300.02) | (25,471.78) | (16,954.16) | (22,292.40) | | | |
| | Outstanding Checks- No Supporting Documents | | | | | | | | | | | | | | | |
| Adjusted Bank Balance | | 222,262.03 | 127,670.27 | 145,995.61 | 69,578.77 | 82,605.69 | 119,582.65 | 109,636.39 | 85,462.09 | 85,312.36 | 95,971.42 | 124,666.52 | 252,176.88 | | | |
| Balance per Cash sheet | | 225,508.59 | 130,663.65 | 146,033.90 | 69,617.04 | 82,605.69 | 119,582.65 | 109,636.39 | | 85,312.36 | 96,029.92 | 124,666.52 | 252,176.88 | | | |
| Add: | Deposit not recorded in Cash Sheet | - | | | | | | | | | | | | | | |
| Less: | Bank charge/errors not recorded in cash Sheet | (3,246.56) | (2,993.38) | (38.29) | (38.27) | | | | | | (58.50) | | | | | |
| Adjusted Cash Sheet Balance | | 222,262.03 | 127,670.27 | 145,995.61 | 69,578.77 | 82,605.69 | 119,582.65 | 109,636.39 | - | 85,312.36 | 95,971.42 | 124,666.52 | 252,176.88 | | | |
| | | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 85462.09 | 0.00 | 0.00 | 0.00 | 0.00 | | | |

**Reference to No Supporting Documents in 2012 ad 2013**

1 Monthly Bank reconciliations Jan-Dec 2012

2 Reconciliation Details as of 30 Sep 2013

| | Date | Voucher No. | Amount -USD |
|---|---|---|---|
| a) Balance broght forward from 2012 | 28-12-12 | 12-0028 | $ 83,000.00 |
| b) Balance brought forward from 2012 | 28-12-12 | 12-3224 | $ 16,720.31 |
| c) Sales Receipt fr NOVIB-Clear SGI to NOVIB | 22-04-13 | 13-0081 | $ 40,000.00 |
| d) Transfer from SGI to Global A/C | 21-08-13 | 13-1776 | $ 25,000.00 |
| e) Sale Receipt fr UNOPS-Clear SGI to UNOPS | 15-08-13 | 13-0161 | $ 20,000.00 |
| f) Transfer SGI to GLOBAL A/C | 12-09-13 | 13-2045 | $ 17,259.51 |
| g) Transfer SGI to GLOBAL A/C | 05-07-13 | 13-1413 | $ 30,000.00 |
| h) Transfer SGI to GLOBAL A/C | 19-06-13 | 13-1200 | $ 20,000.00 |
| i) Transfer SGI to GLOBAL A/C | 02-08-13 | 13-1665 | $ 7,000.00 |
| Total | | | $258,979.82 |